# គន្ធារជាតក



## ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**កុល ផេង** **ព.ស. ២៥៦៤**

# គន្ធារជាតក

រៀបរៀងដោយ

*បណ្ឌិត* **កុល ផេង**

សីល សមាធិ បញ្ញា

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

**ព.ស. ២៥៦៤**

| | |
|---|---|
| ឈ្មោះសៀវភៅ | **គន្ធារជាតក** |
| រៀបរៀងដោយ | បណ្ឌិត **កុល ផេង**<br>ប្រធានពុទ្ធិកបណ្ឌិតសភា<br>នៃសាកលវិទ្យាល័យ<br>បញ្ញាសាស្ត្រកម្ពុជា |
| ទីតាំងធ្វើ | ពុទ្ធិកបណ្ឌិតសភា |
| ការផ្សាយ | របស់ពុទ្ធិកបណ្ឌិតសភា |
| រក្សាសិទ្ធិ | ពុទ្ធិកបណ្ឌិតសភា |
| កាលបរិច្ឆេទ | ថ្ងៃពុធ ៣ រោច ខែ<br>អាសាឍ ឆ្នាំជូត ទោស័ក<br>ព.ស. ២៥៦៤<br>ថ្ងៃទី ៧ ខែ កក្កដា គ.ស.<br>២០២០ |

# គន្ធារជាតក

## បុព្វនិទានជាដើមហេតុនៃជាតក

*សម័យនោះ ព្រះពុទ្ធដ៏ទ្រង់យស កាលគង់ក្នុងវិហារជេតពន ដែលជារបស់អនាថបិណ្ឌិកមហាសេដ្ឋីក្បែរក្រុងសាវត្ថី ។ គ្រានោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុប្រាថ្នានឹងធ្វើទីជ្រកកោន ទើបឲ្យគេជម្រះសំអាតញកភ្នំក្បែរក្រុងរាជគ្រឹះ ។*

*លំដាប់នោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរដ៏មានអាយុ លុះព្រះរាជដំណើរទៅដល់ហើយ ក៏បង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីសមគួរ ។ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់គង់នៅក្នុងទីសមគួរហើយ ទើបមានព្រះរាជឱង្ការនឹងបិលិន្ទវច្ឆត្ថេរដ៏មានអាយុថា លោកម្ចាស់លោកឲ្យគេ*

ធ្វើអ្វី ។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ អាត្មាភាពចង់ធ្វើកន្លែងជ្រកកោន បានជាឲ្យគេជម្រះសំអាតញកភ្នំ ។ ទ្រង់ក៏សួរថា លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រូវការអារាមិកជន (មនុស្សថែទាំរក្សាអារាម) ឬទេ ។ ព្រះថេរៈថ្វាយព្រះពរថា បពិត្រមហារាជ អារាមិកជន ព្រះដ៏ទ្រង់ព្រះភាគ មិនទាន់ទ្រង់អនុញ្ញាតនៅឡើយទេ ។ ទ្រង់ត្រាស់ថា លោកម្ចាស់ បើដូច្នោះ លោកម្ចាស់គួរទូលសួរព្រះដ៏ទ្រង់ព្រះភាគ ហើយសឹមមកប្រាប់ញោម ។ បិលិន្ទវច្ឆត្ថេរដ៏មានអាយុក៏ទទួលព្រះរាជឱង្ការព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈថា ថ្វាយព្រះពរមហារាជ ។

ខណៈនោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុបានពន្យល់ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈឲ្យទ្រង់ឃើញច្បាស់ ឲ្យទ្រង់សមាទាន ឲ្យទ្រង់

ក្បៀវក្លាឲ្យ ទ្រង់រីករាយដោយធម្មីកថា ។ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ដែលបិលិន្ទវច្ឆត្ថេរដ៏មានអាយុបានឲ្យទ្រង់ឃើញជាក់ស្ដែង ឲ្យទ្រង់សមាទាន ឲ្យទ្រង់ក្បៀវក្លា ឲ្យទ្រង់រីករាយ ដោយធម្មីកថាហើយ ទ្រង់ក៏ក្រោកចាកអាសនៈបង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយទ្រង់ធ្វើប្រទក្សិណយាត្រាចេញទៅ ។

លំដាប់នោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុប្រើបម្រើទៅកាន់សំណាក់ព្រះដ៏មានព្រះភាគម្ចាស់ថា បពិត្រព្រះអង្គដ៏ចម្រើនព្រះបាទពិម្ពិសារ សេនិយរាជ ជាធំក្នុងដែនមគធៈទ្រង់ចង់ប្រទានអារាមិកជនឲ្យបពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគួរបដិបត្តិដូចម្ដេច ។ ព្រោះនិទាននេះ ដំណើរនេះព្រះដ៏មានព្រះភាគម្ចាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សម្ដែងធម្មីកថាត្រាស់ហៅ

# គន្ធារជាតក

ភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតអារាមិកជន ។ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរ ដ៏មានអាយុជាគម្រប់ពីរដងលុះយាងចូលទៅហើយ ទើបទ្រង់បង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីសមគួរមួយ ។

លុះព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈគង់ស្រួលបួលហើយ មានព្រះបន្ទូលនឹងបិលិន្ទ-វច្ឆត្ថេរដ៏មានអាយុថា បពិត្រលោកម្ចាស់ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់អនុញ្ញាតអារាមិកជនហើយឬ ។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ ព្រះអង្គបានអនុញ្ញាតហើយ ។ ទ្រង់ត្រាស់ថា បពិត្រលោកដ៏ចម្រើនបើដូច្នោះញោមប្រគេនអារាមិកជនម្នាក់ដល់លោកម្ចាស់ ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជ

# គន្ធារជាតក

ជាធំក្នុងដែនមគធៈទ្រង់ប្ដេជ្ញាថាប្រគេនអាពាមិកជន
ដល់បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយក៏ភ្លេចព្រះស្មារតី
យូរបន្តិចទៅ ទ្រង់រលឹកឃើញវិញ ទើបទ្រង់ត្រាស់
ហៅមហាអាមាត្យម្នាក់ជាអ្នកសម្រេចរាជការទាំងពួង
ថា នែមហាអាមាត្យ អារាមិកជនណាដែលយើង
បម្រុងនឹងប្រគេនលោកម្ចាស់ អារាមិកជននោះ យើង
បានប្រគេនលោកហើយឬ ។ មហាអាមាត្យក្រាបទូល
ថា បពិត្រព្រះសម្មតិទេព អារាមិកជន ទ្រង់មិនទាន់
ប្រគេនដល់លោកម្ចាស់នៅឡើយទេ ។ ស្ដេចត្រាស់
សួរថា នែមហាអាមាត្យ រាប់ពីរាត្រីនេះទៅ បានប៉ុន្មាន
រាត្រីហើយ ។ លំដាប់នោះ មហាអាមាត្យនោះបានរាប់
រាត្រីសព្វគ្រប់ហើយ ក្រាបទូលព្រះបាទពិម្ពិសារ-
សេនិយរាជជាធំក្នុងដែនមគធៈដូច្នេះថា បពិត្រព្រះ
សម្មតិទេព បាន ៥០០ រាត្រីហើយ ។ ស្ដេចត្រាស់ថា

នៃមហាអមាត្យ បើដូច្នេះ អ្នកចូរប្រគេនអារាមិកជន ៥០០ នាក់ទៅលោកម្ចាស់ចុះ ។ មហាអមាត្យនោះ ទទួល ព្រះរាជឱង្ការ ព្រះបាទពិម្ពិសារសេនិយរាជជា ជំក្នុងដែនមគធៈថា សូមទ្រង់មេត្តាប្រោសយ៉ាងហ្នឹង ហើយៗ បានប្រគេនអារាមិកជន ៥០០នាក់ ដល់ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ។ ទីនោះបានជាស្រុកមួយ ផ្សេងដោយឡែក ។ ជនទាំងឡាយហៅស្រុកនោះថា អារាមិកគ្រាមខ្វះ ហៅថាបិលិន្ទវច្ឆគ្រាមខ្វះ ។

សម័យនោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុជា ជីតុនក្នុងស្រុកនោះ ។ គ្រានោះ បិលិន្ទវច្ឆត្ថេរដ៏មាន អាយុស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរចូលទៅ បិណ្ឌបាតក្នុងបិលិន្ទវច្ឆគ្រាម នាវេលាព្រឹកព្រហាម ។ សម័យនោះឯង មានល្បែងមហោរស្រពក្នុងស្រុក នោះ ។ ពួកក្មេង ៗ បានប្រដាប់តាក់តែងដោយ

ផ្កាកម្រងលេងមហោរស្រព ។ លំដាប់នោះបិលិន្ទវច្ឆត្ថេរដ៏មានអាយុកំពុងត្រេចទៅបិណ្ឌបាត តាមលំដាប់ច្រកក្នុងបិលិន្ទវច្ឆគ្រាម បានចូលទៅកាន់លំនៅរបស់អារាមិកជនម្នាក់ លុះចូលទៅហើយ ទើបអង្គុយលើអាសនៈដែលគេរៀបចំប្រគេន ។ សម័យនោះឯងធីតារបស់ស្រីរក្សាអារាមនោះឃើញទារកឯទៀតៗប្រដាប់តាក់តែងដោយផ្កាកម្រង ហើយក៏យំសុំថា ម៉ែចូរឲ្យផ្កាកម្រងមកខ្ញុំ ម៉ែចូរឲ្យគ្រឿងប្រដាប់ មកខ្ញុំ ។ គ្រានោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ បាននិយាយពាក្យនេះនឹងស្រីរក្សាអារាមនោះថា នាងទារិកានេះយំទារអ្វី ។ ស្រីរក្សាអារាម ទូលថាលោកម្ចាស់ នាងទារិកានេះឃើញទារកឯទៀត ៗ ប្រដាប់តាក់តែង ដោយផ្កាកម្រង បានជាយំទារថា ម៉ែចូរឲ្យផ្កាកម្រងមកខ្ញុំ ម៉ែចូរឲ្យគ្រឿងប្រដាប់មកខ្ញុំ យើងខ្ញុំជាអ្នកក្រលំបាក នឹង

បានផ្កាកម្រងមកពីណា នឹងបានគ្រឿងប្រដាប់មកពីណា ។ ខណៈនោះបិលិន្ទវច្ឆត្ថេរ ដ៏មានអាយុចាប់រង្វើលស្មៅ ១ ហើយនិយាយពាក្យនេះនឹងស្រីរក្សាអារាមនោះថា ហ៎! នាងចូរបំពាក់រង្វើលស្មៅនេះលើក្បាលរបស់ក្មេងស្រីនោះចុះ ។ ពេលនោះ ស្រីរក្សាអារាមនោះ យករង្វើលស្មៅនោះបំពាក់លើក្បាលរបស់នាងទារិកានោះ ។ រង្វើលស្មៅនោះក៏ក្លាយជាកម្រងមាសល្អល្អះ មុខគួរពិតពិលរមិលមើល ជារបស់គួរស្រឡាញ់ ។ កម្រងមាសបែបនោះ សូម្បីក្នុងព្រះរាជវាំងស្តេច ក៏រកគ្មានដែរ ។ មនុស្សទាំងឡាយទៅក្រាបទូល ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈថា បពិត្រសម្មតិទេព កម្រងមាសក្នុងផ្ទះរបស់អារាមិកជនឯណោះល្អល្អះ មុខគួរពិតពិលរមិលមើល ជារបស់គួរស្រឡាញ់ សូម្បីក្នុងព្រះរាជវាំងរបស់ព្រះ

អង្គក៏ពុំមានកម្រងមាសដូច្នោះ ដែរមនុស្សខ្សត់ទុរគត នោះនឹងបានកម្រងមាសមកពីណា ច្បាស់ជាវាលួចយករបស់គេ ជាប្រាកដ ។

គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែលមគធៈទ្រង់ឲ្យរាជបុរស ទៅកោះពួកត្រកូលអារាមិកជននោះមក ។ វេលាព្រឹកព្រហាម បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រ នឹងចីវរចូលទៅបិណ្ឌបាតនាបិលិន្ទវច្ឆគ្រាមជាគម្រប់ពីរដង កាលដើរទៅបិណ្ឌបាតក្នុង បិលិន្ទវច្ឆគ្រាមជាលំដាប់ៗទៅ ទើបចូលទៅកាន់លំនៅរបស់អារាមិកជននោះ លុះចូលទៅដល់ហើយ សួរពួកជនដែលជាទីស្និទ្ធស្នាលថា ត្រកូលអារាមិកជននេះទៅណាទៅ ។ ពួកជនពិតថា លោកម្ចាស់ស្តេចឲ្យរាជបុរស មកចាប់ចងយកទៅហើយ ព្រោះហេតុតែកម្រងមាសនោះឯង។

# គន្ធារជាតក

លំដាប់នោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ក៏ចូលទៅកាន់ព្រះរាជនិវេសន៍របស់ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ លុះទៅដល់ហើយគង់លើអាសនៈដែលគេតាក់តែងប្រគេន ។ គ្រានោះព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរដ៏មានអាយុ លុះដល់ហើយក៏ថ្វាយបង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីសមគួរ ។

លុះព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់គង់ស្រួលបួលហើយ ទើបបិលិន្ទវច្ឆត្ថេរដ៏មានអាយុថ្វាយព្រះពរថា បពិត្រមហារាជ ហេតុអ្វីបានជាព្រះអង្គឲ្យរាជបុរសទៅចាប់ ត្រកូលអារាមិកជនមកឃុំ ។ ព្រះបាទពិម្ពិសារត្រាស់ថា លោកម្ចាស់នាផ្ទះរបស់ អារាមិកជននោះ មានកម្រងមាសល្អល្អះ

មុខគួរពិតពិលរមិលមើលជារបស់មានតម្លៃ សូម្បីក្នុងវាំងរបស់ញោម ក៏មិនមានកម្រងមាសដូច្នោះដែរ អ្នកខ្សត់ទុរគតនោះ នឹងបានកម្រងមាសមកពីណា ច្បាស់ជាវាលួចយករបស់គេហើយ ។

ខណៈនោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុក៏អធិដ្ឋាន ប្រាសាទរបស់ព្រះបាទពិម្ពិសារសេនិយរាជជាធំ ក្នុងដែនមគធៈ ឲ្យក្លាយជាមាសទៅ ។ ប្រាសាទទាំងនោះក៏ក្លាយទៅជាមាសទាំងអស់ ។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ មាសនេះច្រើនដល់ម្ល៉េះ ព្រះអង្គបានមកពីណា ។ ស្តេចត្រាស់ថាខ្ញុំមិនដឹងទេ លោកម្ចាស់ របស់ទាំងនេះប្រហែលជាសម្រេចដោយឥទ្ធានុភាព របស់លោកម្ចាស់ទេដឹង ហើយត្រាស់ឲ្យដោះលែងត្រកូលអារាមិកជននោះទៅ ។

# គន្ធារជាតក

មនុស្សទាំងឡាយឮដំណឹងថា បិលិន្ទវច្ឆត្ថេរជាម្ចាស់ បានសម្ដែងឥទ្ធិបាដិហារិយៈ (ឥទ្ធិឫទ្ធិដ៏អស្ចារ្យចំឡែក) ជាមនុស្សធម៌ដ៏ខ្ពង់ខ្ពស់ដល់បរិសទ្យ ព្រមទាំងព្រះរាជា ហើយក៏មានចិត្តត្រេកអរជ្រះថ្លា នាំយកនូវភេសជ្ជៈ៥ យ៉ាងមកបូជាបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ភេសជ្ជៈ ៥ នោះគឺ សប្បិ (ទឹកដោះរាវ) នវនីតៈ (ទឹកដោះខាប់) តេលៈ (ប្រេង) មធុ (ទឹកឃ្មុំ) ផាណិតៈ (ទឹកអំពៅឬស្ករអំពៅ) ។ ឯបិលិន្ទវច្ឆត្ថេរដ៏មានអាយុតែងបានភេសជ្ជៈ ៥ ហើយរមែងចែករបស់ដែលលោកបានមកៗ ទៅដល់បរិសទ្យ (សិស្សរបស់លោក) ដោយប្រក្រតី ។ ឯបរិសទ្យរបស់ លោកនោះតែងបានភេសជ្ជៈទាំងនោះច្រើនរឿយៗ បានដាក់ទុករបស់ដែលបានមកៗ ក្នុងថ្លាងផង ក្នុងក្អមផង ខ្ចប់នឹងសំពត់សម្រាប់ត្រងទឹកផង ទុកក្នុងថង់យាមផង ត្រាតែពេញ ហើយ

ព្យួរទុកតាមបង្អួចដេរដាស ។ កេសជ្ជៈទាំងនោះក៏សើមលេចហៀរចេញពាសពេញ ។ វិហារទាំងឡាយក៏ដេរដាសពាសពេញដោយសត្វកណ្ដុរទាំងឡាយ ។ មនុស្សទាំងឡាយ កាលដើរទៅកាន់វិហារចារិក បានឃើញហើយទើបពោលទោស តិះដៀល បន្ទុះបង្អាប់ថា សមណៈពួកនេះជាកូនចៅព្រះពុទ្ធសក្យបុត្រមានភណ្ឌៈតម្កល់ទុកក្នុងឃ្លាំងដូចជាព្រះបាទពិម្ពិសារ-សេនិយរាជជាធំក្នុងដែនមគធៈដែរ ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្ទុះបង្អាប់ហើយ ។ ពួកភិក្ខុណាជាអ្នកមានសេចក្ដីប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា មិនសមបើពួកភិក្ខុមកព្យាយាមដើម្បីសេចក្ដីល្មោភច្រើនមានសភាពដូច្នេះឡើយ ។ ទើបពួកភិក្ខុទាំងនោះនាំសេចក្ដីនុ៎ះ ទៅក្រាប

# គន្ធារជាតក

ទូលដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុព្យាយាមដើម្បីសេចក្ដីល្មោភច្រើនមានសភាពដូច្នេះ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មិនសមបីបើពួកមោឃបុរសទាំងនោះមកព្យាយាម ដើម្បីសេចក្ដីល្មោភច្រើនមានសភាពដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកបានធ្វើមកនេះ មិនមែននាំឲ្យកើតជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬថែមសេចក្ដីជ្រះ ថ្លាដល់ជនទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទៅទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

# គន្ធារជាតក

យានិ ខោ បន តានិ គិលានានំ ភិក្ខូនំ បដិសាយនីយានិ ភេសជ្ជានិ សេយ្យថិទំ? សប្បិ នវនីតំ តេលំ មធុ ផាណិតំ តានិ បដិគ្គហេត្វា សត្តាហបរមំ សន្និធិការកំ បរិភុញ្ជិតព្វានិ។ តំ អតិក្កាមយតោ និស្សគ្គិយំ ចាចិត្តិយំ។

*ភេសជ្ជៈណាមួយ ដែលពួកភិក្ខុមានជំងឺគប្បីឆាន់បាន ភេសជ្ជៈនេះគឺ ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ។ ភិក្ខុទទួលភេសជ្ជៈទាំងនោះហើយ គួរទុកឆាន់បានយ៉ាងយូរត្រឹម ៧ ថ្ងៃ បើភិក្ខុទុកឲ្យកន្លងកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយ-បាចិត្តិយៈ ។*

## បច្ចុប្បន្ននិទាន

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ* ភេសជ្ជសន្និធិការសិក្ខាបទ *នេះ*

# **គន្ធារជាតក**

*(សិក្ខាបទពោលដោយការសន្សំភេសជ្ជៈ)*[១] *ទើបត្រាស់* ***គន្ធារជាតកនេះ*** *មានពាក្យផ្ដើមថា* **ហិត្វា គាម-សហស្សានិ** *ដូច្នេះជាដើម ។*

*រឿងបានកើតឡើងហើយ នៅក្នុងក្រុងរាជគ្រឹះ។ សេចក្ដីពិស្ដារថា កាលព្រះបិលិន្ទវច្ឆៈ ទៅកាន់ព្រះរាជវាំង ដើម្បីដោះលែងមនុស្ស ក្នុងត្រកូលអ្នករក្សាអារាម បានធ្វើប្រាសាទមាសដោយកម្លាំងឫទ្ធិដល់ព្រះរាជាហើយ មនុស្សទាំងឡាយជ្រះថ្លា នាំគ្នាបញ្ជូនភេសជ្ជៈ ៥*[(២)] *ទៅប្រគេនព្រះថេរៈ ។ ព្រះថេរៈចែកចាយភេសជ្ជៈទាំងនោះដល់បរិស័ទ ប៉ុន្តែបរិស័ទរបស់*

---

*១. បិ. ៣ ទំ. ១៦៧ ។ (២). ភេសជ្ជៈ ៥ នោះគឺ* ***សប្បិ*** *(ទឹកដោះរាវ)* ***នវនីតៈ*** *(ទឹកដោះខាប់)* ***តេលៈ*** *(ប្រេង)* ***មធុ*** *(ទឹកឃ្មុំ)* ***ផាណិតៈ*** *(ទឹកអំពៅ ឬស្ករអំពៅ) ។*

# គន្ធារជាតក

ព្រះថេរៈមានសេចក្តីប្រាជ្ញាច្រើន ពួកលោកទុក ភេសជ្ជៈ ដែលបានមកហើយពេញប៉ោតទឹកខ្លះ ថ្លាំង ខ្លះ ស្ទោកបាត្រខ្លះ ។ មនុស្សទាំងឡាយឃើញដូច្នោះ ក៏ពោលទោសថា សមណៈទាំងនេះប្រាជ្ញាច្រើន ជា អ្នករក្សាឃ្លាំងទុកខាងក្នុង ។ ព្រះសាស្តាទ្រង់ព្រះ សណ្តាប់នូវរឿងនោះហើយ ទ្រង់បញ្ញត្តសិក្ខាបទថា "**យានិ ខោ បន តានិ គិលានានំ ភិក្ខូនំ** ក៏ភេសជ្ជៈ ដែលជារបស់គួរគ្រេបផឹករបស់ភិក្ខុអ្នកមានជំងឺទាំង នោះណា"[១] ដូច្នេះជាដើម ហើយទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បណ្ឌិតកាលពីមុន កាលព្រះពុទ្ធ មិនទាន់ត្រាស់ដឹងឡើងក្នុងលោក បួសក្នុងលទ្ធិខាង ក្រៅ សូម្បីរក្សាត្រឹមតែសីល ៥ ក៏មិនបានរក្សាដុំអំបិល

[១]. បិ. ៣ ទំ. ១៧៥ ។

ទុក ដើម្បីប្រយោជន៍ក្នុងថ្ងៃស្អែកដែរ ចំណែកអ្នកទាំងឡាយបួសក្នុងសាសនា ដែលជាសាសនានាំសត្វចេញចាកទុក្ខបែបនេះ កាលនាំគ្នាធ្វើការសន្សំអាហារទុក ដើម្បីប្រយោជន៍ដល់ថ្ងៃទី២ ថ្ងៃទី៣ ឈ្មោះថា ធ្វើអំពើដែលមិនសមគួរ" លុះទ្រង់ត្រាស់ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

## អតីតនិទាន

ក្នុងអតីតកាល ព្រះបរមពោធិសត្វទ្រង់ជាឱរសរបស់ព្រះបាទ**គន្ធារៈ**ក្នុងដែនគន្ធាររដ្ឋ ស្ដេចឡើងគ្រប់គ្រងរាជសម្បត្តិ ដោយព្រះរាជបិតាសោយទិវង្គតទៅ ទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ ។ ចំណែកនៅក្នុងមជ្ឈិមប្រទេស ព្រះបាទ**វិទេហៈ**ទ្រង់គ្រងរាជ្យក្នុងវិទេហរដ្ឋ ។ ព្រះរាជាទាំង ២ ព្រះអង្គនោះ ទ្រង់ជា

សម្លាញ់នឹងគ្នា ដែលមិនធ្លាប់ឃើញគ្នា ប៉ុន្តែទ្រង់មាន សេចក្តីស្និទ្ធស្នាលគ្នាយ៉ាងក្រៃលែង ។ មនុស្សក្នុង សម័យនោះ មានអាយុរស់នៅដល់ទៅ ៣ ម៉ឺនឆ្នាំ ។ ក្នុងថ្ងៃ**បុណ្ណមុបោសថ** (ឧបោសថថ្ងៃ ១៥ កើតពេញ បូណ៌មី) ព្រះបាទគន្ធារៈ ទ្រង់សមាទានសីលហើយ ស្តេចយាងទៅគង់នៅកណ្តាល**បញ្ញត្តវរបល្ល័ង្ក** ក្នុង មហាតលដ្ឋាន (មហារោង) ទ្រង់ត្រួតមើលលោកធាតុ ទិសខាងកើត តាមសីហបញ្ជរ ដែលបើកទុក ទ្រង់ ត្រាស់ពាក្យដែលប្រកបដោយធម៌ទៅកាន់ពួកអាមាត្យ។ ខណៈនោះ រាហូបានបិទបាំងមណ្ឌលព្រះចន្ទ្រ បីដូច ជាលោតកន្ទង់នូវផ្ទៃមេឃ ពន្លឺព្រះចន្ទក៏អន្តរធានទៅ ។ អាមាត្យទាំងឡាយមិនឃើញព្រះចន្ទ ក៏ទូលព្រះរាជា អំពីរឿងដែលព្រះចន្ទត្រូវរាហូចាប់ ។ ព្រះរាជាសម្លឹង

មើលព្រះចន្ទ ក៏ទ្រង់ព្រះតម្រិះថា "ព្រះចន្ទនេះ សៅហ្មង អប្បរស្មី ព្រោះវត្ថុសៅហ្មងដែលចរមក, សូម្បីរាជបរិវារទាំងនេះ ក៏ជាគ្រឿងសៅហ្មងសម្រាប់យើងដែរ ការដែលយើងជាអ្នកអស់ពន្លឺគ្មានរស្មី ដូចព្រះចន្ទដែលត្រូវរាហូចាប់នោះ មិនសមគួរដល់យើងឡើយ, យើងនឹងលះបង់រាជសម្បត្តិចេញបួស ដូចដួងចន្ទសញ្ចរទៅក្នុងផ្ទៃមេឃដ៏បរិសុទ្ធដូច្នោះដែរ នឹងមានប្រយោជន៍អ្វីដោយអ្នកដទៃ ដែលយើងត្រូវក្រើនរលឹក យើងនឹងធ្វើខ្លួនឲ្យជាអ្នកមិនជាប់ជំពាក់ក្នុងត្រកូល និងពួកគណៈ ដាស់តឿនក្រើនរលឹកខ្លួនឯងប៉ុណ្ណោះ នេះអំពើក៏សមគួរសម្រាប់យើង" លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ទ្រង់ប្រគល់រាជសម្បត្តិឲ្យពួកអាមាត្យ ដោយព្រះតម្រាស់ថា អ្នកទាំងឡាយចូរនាំ

គ្នាតែងតាំងអ្នក ដែលអ្នកទាំងឡាយត្រូវការ ឲ្យធ្វើជាព្រះរាជាចុះ ។ ព្រះរាជាក្នុងគន្ធាររដ្ឋនោះទ្រង់លះបង់រាជសម្បត្តិ ទ្រង់ព្រះផ្នួសជាតសី ញុំាងឈាននិងអភិញ្ញាឲ្យកើតឡើងហើយ ទ្រង់ផ្ទេតស្កប់ស្កល់ដោយសេចក្តីត្រេកអរក្នុងឈាន សម្រេចការនៅក្នុងដែនដីនៃព្រៃហិមពាន្ត ។

ចំណែកព្រះបាទវិទេហៈត្រាស់សួរពួកឈ្មួញទាំងឡាយថា ព្រះរាជា ជាសម្លាញ់របស់យើងសុខសប្បាយទេឬ ។ ទ្រង់ស្តាប់នូវភាពជាបព្វជិតរបស់ព្រះបាទគន្ធារៈហើយ ក៏ទ្រង់ព្រះតម្រិះថា កាលសម្លាញ់របស់យើងទ្រង់ផ្នួសហើយ តើយើងនឹងធ្វើយ៉ាងណា ចំពោះរាជសម្បត្តិ លុះទ្រង់ព្រះតម្រិះដូច្នេះហើយក៏ទ្រង់លះបង់រាជសម្បត្តិ ក្នុងមិថិលនគរ ដែល

# គន្ធារជាតក

មានទំហំ ៧ យោជន៍ ឃ្លាំងដែលពេញ នៅក្នុង ស្រុក ១៦០០០ ក្នុងវិទេហរដ្ឋ ដែលមានប្រមាណ ៣០០ យោជន៍ និងស្រីរបាំ ១៦០០០នាក់ ទ្រង់មិននឹក ដល់ព្រះរាជឱរស និងព្រះរាជធីតា ស្តេចយាងទៅ កាន់ព្រៃហិមពាន្តទ្រង់ព្រះផ្នួស សោយផ្លែឈើតាម ដែលមាន ទ្រង់គង់នៅមិនជាប្រចាំក្នុងទីណាមួយ ត្រាច់សញ្ចរទៅកាន់ទីទាំងពួង ។ តាបសទាំង ២ នោះ ប្រព្រឹត្តវត្តនិងអាចារៈស្មើគ្នា ក្រោយមក ក៏បានជួបគ្នា តែលោកទាំងពីរមិនស្គាល់គ្នា ក៏ជាអ្នករីករាយរកគ្នា ប្រព្រឹត្តវត្តនិងអាចារៈក៏ស្មើគ្នា ។ កាលនោះ វិទេហ-តាបស បម្រើគន្ធារតាបស ។ ក្នុងថ្ងៃពេញបូណ៌មីថ្ងៃ មួយ កាលតាបសទាំង ២ នោះ គង់ពោលកថា ដែល ប្រកបដោយធម៌ជាមួយគ្នា នៅក្រោមដើមឈើមួយ

# គន្ធារជាតក

ដើម រាហូបិទបាំងដួងចន្ទដែលអណ្តែតនៅលើមេឃ ។ វិទេហតាបសគិតថា ពន្លឺព្រះចន្ទបាត់ទៅ ព្រោះអាស្រ័យអ្វីហ្ន៎! ក៏ក្រឡេកមើលឃើញព្រះចន្ទត្រូវរាហូចាប់ទុក ក៏សួរថា បពិត្រអាចារ្យ អ្វីបានបិទបាំងព្រះចន្ទ ធ្វើឲ្យអស់រស្មីនោះ ។ គន្ធារតាបសឆ្លើយថា ម្នាលអន្តេវាសិក នេះឈ្មោះថា រាហូ ជាគ្រឿងសៅហ្មងមួយរបស់ព្រះចន្ទ មិនឲ្យព្រះចន្ទមានពន្លឺរស្មីទេ ចំណែកយើងឃើញដួងចន្ទ ត្រូវរាហូបិទបាំងហើយ ក៏គិតថា ដួងចន្ទដែលបរិសុទ្ធនេះ ក៏ក្លាយទៅជាអស់ពន្លឺរស្មីទៅវិញ ព្រោះគ្រឿងសៅហ្មងដែលចរមក រាជសម្បត្តិនេះក៏ជាគ្រឿងសៅហ្មង សម្រាប់យើងដែរ យើងនឹងបួសដើម្បីមិនឲ្យរាជសម្បត្តិធ្វើយើងឲ្យអប្បរស្មី ដែលដូចព្រះចន្ទត្រូវរាហូចាប់ឡើយ លុះគិតហើយ ក៏ធ្វើ

# គន្ធារជាតក

ដូងចន្ទដែលត្រូវរាហូធ្វើឲ្យអស់ពន្លឺនោះឲ្យជាអារម្មណ៍ បានលះបង់រាជសម្បត្តិដ៏ធំ ហើយចេញបួស ។

វិទេហតាបសសួរថា បពិត្រអាចារ្យ លោកជាព្រះបាទគន្ធារៈឬ?

គន្ធារតាបសឆ្លើយថា ត្រូវហើយ ខ្ញុំជាព្រះបាទគន្ធារៈ ។

**វិទេហតាបស.** បពិត្រអាចារ្យ ខ្ញុំខ្លួនឯងឈ្មោះថា ព្រះបាទវិទេហៈ ក្នុងមិថិលានគរក្នុងវិទេហរដ្ឋដែរ ពួកយើងជាសម្លាញ់ ដែលមិនធ្លាប់ឃើញគ្នាពីមុនមក មិនមែនឬ ?

**គន្ធារតាបស.** ក៏អ្នកមានអ្វីជាអារម្មណ៍ ទើបចេញបួស ។

# គន្ធារជាតក

***វិទេហតាបស.*** *ខ្ញុំបានដឹងថា លោកបួសហើយ ទើបគិតថា លោកគង់នឹងបានឃើញគុណដ៏ធំនៃការបួសជាពិតប្រាកដ ទើបធ្វើលោកនោះឯងឲ្យជាអារម្មណ៍ ហើយលះបង់រាជសម្បត្តិចេញបួស ។*

*តាំងពីនោះមក តាបសទាំងពីរនោះ សាមគ្គីរីករាយរកគ្នាខ្លាំងណាស់ ជាអ្នកមានផ្លែឈើដែលរកបានជាភោជនាហារ ។ តាបសទាំងពីរនោះ នៅជាមួយគ្នាទីនោះអស់កាលយូរ ទើបនាំគ្នាចុះចាកព្រៃហិមពាន្ត ដើម្បីត្រូវការរសជូរប្រៃ ទៅដល់ស្រុកជាយដែនមួយ មនុស្សទាំងឡាយជ្រះថ្លាក្នុងឥរិយាបថរបស់លោក ប្រគេនភិក្ខា ឲ្យទទួលការបដិញ្ញាហើយ នាំគ្នាកសាងទីសម្រាប់ពេលថ្ងៃ និងទីសម្រាកពេលយប់ជាដើម ឲ្យលោកនៅក្នុងព្រៃ សូម្បីនៅតាមផ្លូវ ក៏នាំគ្នា*

# គន្ធារជាតក

កសាងបណ្ណសាលាទុក ក្នុងទីដែលមានទឹកងាយស្រួលដើម្បីត្រូវការឲ្យលោកធ្វើភត្តកិច្ច ។ តាបសទាំងពីរនោះ ត្រាច់ភិក្ខាចារក្នុងស្រុកជាយដែននោះហើយ គង់ឆាន់ក្នុងបណ្ណសាលានោះហើយ ទើបទៅកាន់លំនៅរបស់ខ្លួន ។ មនុស្សទាំងនោះ កាលប្រគេនអាហារដល់តាបសនោះ ពេលខ្លះក៏ដាក់អំបិលក្នុងបាត្រ ពេលខ្លះវេចនឹងស្លឹកឈើប្រគេន ពេលខ្លះប្រគេនអាហារដែលមានរសជាតិសាប ។ ថ្ងៃមួយ ពួកគេបានប្រគេនអំបិលជាច្រើន ក្នុងកញ្ចប់ស្លឹកឈើចំពោះតាបសទាំងពីររូបនោះ ។ វិទេហតាបសកាន់យកអំបិលទៅជាមួយ ពេលដល់ភត្តកិច្ចរបស់ព្រះពោធិសត្វ ក៏ប្រគេនល្មមប្រមាណ ចំណែកខ្លួនឯងក៏ចាប់យកប្រមាណសមគួរ សល់អំពីសេចក្ដីត្រូវការ ក៏

## គន្ធារជាតក

វេចខ្ចប់ទុកក្នុងកញ្ចប់ស្លឹកឈើ ដាក់ទុកក្នុងចន្លោះដើមស្មៅ ដោយគិតថា នឹងប្រើប្រាស់ក្នុងថ្ងៃដែលមិនមានអំបិល ។ ថ្ងៃមួយ កាលបានអាហារសាប វិទេហ-តាបសប្រគេនភាជនភិក្ខា ដល់គន្ធារតាបសហើយ នាំអំបិលចេញមកអំពីចន្លោះដើមស្មៅ ហើយពោលថា "អាចារ្យ និមន្តលោកទទួលអំបិល" ។ គន្ធារតាបសសួរថា "ថ្ងៃនេះ មនុស្សទាំងឡាយ មិនបានប្រគេនអំបិលទេ អ្នកបានអំបិលអំពីទីណា" ។

វិទេហតាបសពោលថា "បពិត្រអាចារ្យ ថ្ងៃមុនមនុស្សទាំងឡាយ បានប្រគេនអំបិលច្រើន ខ្ញុំក៏រក្សាអំបិល ដែលនៅសល់ទុកដោយតាំងចិត្តថា នឹងប្រើក្នុងថ្ងៃដែលអាហារមានរសសាប" ។

# គន្ធារជាតក

លំដាប់នោះ ព្រះពោធិសត្វគំរាមវិទេហតាបស ថា "នែមោឃបុរស អ្នកលះបង់វិទេហរដ្ឋប្រមាណ ៣០០ យោជន៍ ហើយដល់នូវការមិនមានកង្វល់អ្វី ពេលនេះមកញ៉ាំងតណ្ហាឲ្យជាប់ក្នុងដុំអំបិលទៀតឬ" កាលនឹងឲ្យឱវាទ ទើបពោលគាថា ទី ១ ថា

ហិត្វា គាមសហស្សានិ
បរិបុណ្ណានិ សោឡស
កោដ្ឋាគារានិ ផីតានិ
សន្និធឹ ទានិ កុព្វសិ ។

អ្នកលះបង់នូវស្រុកចំណុះ ១ ពាន់ និងឃ្លាំង ១៦ ដ៏ពេញបរិបូណ៌ ( ដោយទ្រព្យ ) ធ្វើនូវការសន្សំ ក្នុងកាលឥឡូវនេះ ។

## គន្ធារជាតក

វិទេហតាបសត្រូវគន្ធារតាបសតិះដៀលយ៉ាងនេះ មិនអាចអត់ទ្រាំនឹងពាក្យតិះដៀលបាន ក៏ក្លាយទៅជាបដិបក្ខនឹងគន្ធារតាបស កាលនឹងជំទាស់ថា "នៃលោកអាចរ្យ លោកមិនឃើញទោសរបស់ខ្លួនឯងទេឬ ឃើញតែទោសរបស់ខ្ញុំប៉ុណ្ណោះ លោកគិតថា 'យើងនឹងមានប្រយោជន៍អ្វីដោយមានអ្នកដទៃប្រៀនប្រដៅនោះ យើងនឹងដាស់តឿនខ្លួនឯង' លោកលះបង់រាជសម្បត្តិហើយបួស ប៉ុន្តែឥឡូវនេះ ព្រោះហេតុអ្វី ក៏លោកមកប្រៀនប្រដៅខ្ញុំ" ដូច្នេះហើយក៏ទើបពោលគាថា ទី ២ ថា

ហិត្វា គន្ធារវិសយំ
បហូតធនធារិយំ

## **គន្ធារជាតក**

បសាសនតោ និក្ខន្តោ

ឥធ ទានិ បសាសសិ ។

*អ្នកលះបង់នូវដែនគន្ធារៈ ដែលជាដែនសម្បូណ៌ ដោយទ្រព្យនិងទឹក ហើយចេញផុតអំពីទីជាទីឲ្យនូវពាក្យប្រៀនប្រដៅ ( ដូចខ្ញុំដែរ ) ឥឡូវនេះ ( ហេតុអ្វីក៏មក ) ប្រៀនប្រដៅ ( យើង ) ក្នុងព្រៃនេះ ។*

*ព្រះពោធិសត្វបានស្ដាប់ពាក្យនោះហើយ ទើបពោលគាថា ទី ៣ ថា*

ធម្មំ ភណាមិ វេទេហ

អធម្មោ មេ ន រុច្ចតិ

ធម្មំ មេ ភណមានស្ស

ន បាបមុបលិម្បតិ ។

# គន្ធារជាតក

ម្នាលវិទេហៈ ខ្ញុំនិយាយចំពោះតែធម៌ សភាវៈមិនមែនជាធម៌ មិនគាប់ចិត្តខ្ញុំទេ កាលបើខ្ញុំនិយាយធម៌ បាបឥតប្រឡាក់ទេ ។

បទថា **កាលបើខ្ញុំនិយាយធម៌ បាបឥតប្រឡាក់ទេ** សេចក្ដីថា កាលបើយើងពោលសភាវៈនោះឯង ឬហេតុនោះឯង បាបនឹងមិនជាប់ក្នុងចិត្ត ធម្មតាការឲ្យឱវាទនេះជាប្រពៃណីរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះពុទ្ធសាវក និងព្រះពោធិសត្វទាំងឡាយ ។ សូម្បីបុគ្គលពាលនឹងមិនទទួលយកនូវឱវាទ ដែលលោកទាំងនោះឱ្យហើយ ប៉ុន្តែអ្នកឲ្យឱវាទ ក៏មិនមានបាបដែរ ។ (កាលនឹងសម្ដែងធម៌ ទើបពោលគាថា ថា)

ឯិជីឯំវ បវត្ដាវំ,
យំ បស្សេ វជ្ជទស្សិនំ;

# គន្ធារជាតក

និគ្គយ្ហវាទឹំ មេធាវឹំ,
តាទិសំ បណ្ឌិតំ ភជេ;
តាទិសំ ភជមានស្ស,
សេយ្យោ ហោតិ ន បាបិយោ។

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោសថា ដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នេះ គួរគប់អ្នកប្រាជ្ញបែបនោះ (ព្រោះថា) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

(បិ. ៥២ ទំ. ៣៧)

ឱវទេយ្យានុសាសេយ្យ,
អសព្ភា ច និវារយេ;

# គន្ធារជាតក

សតញ្ហិ សោ បិយោ ហោតិ,
អសតំ ហោតិ អប្បិយោ។

*បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់ នូវជនទាំងឡាយ ចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។*

(បិ. ៥២ ទំ. ៣៨)

*វិទេហតាបសស្តាប់ពាក្យ របស់ព្រះពោធិសត្វនោះហើយ ពោលថា "បពិត្រអាចារ្យ បុគ្គលកាលពោលពាក្យដើម្បីប្រយោជន៍ ក៏មិនគួរពោលពាក្យចាក់ដោតអ្នកដទៃទេ លោកពោលពាក្យគ្រោតគ្រាតខ្លាំងណាស់ ដូចកោរសក់ដោយកាំបិតដែលមិនមុតដូច្នោះ" លុះពាក្យយ៉ាងនេះហើយ ទើបបានពោលគាថាទី ២ ថា*

# គន្ធារជាតក

យេន កោនចិ វណ្ណេន

បរោ លភតិ រុប្បនំ

មហត្ថិយម្បិ ចេ វាចំ

ន តំ ភាសេយ្យ បណ្ឌិតោ ។

*បុគ្គលដទៃបាននូវសេចក្តីក្រោធ ព្រោះពាក្យណានីមួយ បណ្ឌិតមិនគួរពោលពាក្យនោះឡើយ បើទុកជាពាក្យមាន ប្រយោជន៍ដ៏ធំក៏ដោយ ។*

*លំដាប់នោះ ព្រះពោធិសត្វក៏ពោលគាថាទី៥ តបទៅនឹងវិទេហតាបសនោះថា*

កាមំ រុប្បតុ វា មា វា

ភុសំវ វិកិរីយតុ

ធម្មំ មេ ភណមានស្ស

ន ចាបមុបលិម្បតិ ។

# គន្ធារជាតក

*បុគ្គលទោះខឹងក៏ដោយ មិនខឹងក៏ដោយ ទោះរោយ រាយដូចអង្កាមក៏ដោយ កាលបើខ្ញុំនិយាយធម៌បាបមិនប្រឡាក់បានទេ ។*

*ព្រះពោធិសត្វលុះពោលយ៉ាងនេះហើយ បានតាំងនៅក្នុងវត្តបដិបត្តិដ៏សមគួរដល់ឱវាទរបស់ព្រះសុគតនេះ ថា*

ន រោ អហំ អានន្ទ តថា បរក្កមិស្សាមិ,

យថា កុម្ភការោ

អាមកោ អាមកាមត្តេ។

និគ្គយ្ហ និគ្គយ្ហាហំ អានន្ទ វក្ខាមិ,

យោ សារោ សោ ឋស្សតិ។

# គន្ធារជាតក

ម្នាលអានន្ទ ស្មូនឆ្នាំង កាន់ភាជន៍ទទឹកមិនទាន់ស្ងួត ( ថ្នមមិនឲ្យបែក ) យ៉ាងណា តថាគត មិនបៀតបៀនអ្នកទាំងឡាយ យ៉ាងនោះដែរ ។

ម្នាលអានន្ទ តថាគតសង្កត់សង្កិនហើយ ប្រៀនប្រដៅរឿយៗ ម្នាលអានន្ទ តថាគតបន្សាត់បង់ បំផ្លាញបង់នូវទោសចេញហើយ ប្រៀនប្រដៅថែមទៀត ដោយគិតថា នឹងឲ្យអ្នកទាំងឡាយ មានសារៈគឺមគ្គផល តាំងនៅក្នុងសន្តាន[១] ។

កាលនឹងដាស់តឿនវិទេហតាបសទៀត ដើម្បីសម្ដែងឲ្យឃើញថា "អ្នកដាស់តឿនហើយ សង្កត់សង្កិនហើយ ៗ ទើបទទួលបុគ្គលទាំងឡាយ ប្រៀប

---

[១]. សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក សុញ្ញតវគ្គ មហាសុញ្ញតសូត្រ បិដកលេខ ២៧ ទំព័រ ៣៨-៣៩ ។

# គន្ធារជាតក

ដូចជាផ្ទាំងដី ដែលដុតឆ្អិនហើយ ត្រូវស្ទូនផ្ទាំងគោះមើលហើយ គោះមើលទៀត មិនទទួលយកភាជនៈដីដែលមិនទាន់ឆ្អិន ទទួលយកតែភាជនៈដី ដែលដុតឆ្អិនហើយប៉ុណ្ណោះ” លុះពោលដូច្នោះហើយ ទើបពោលគាថា ២គាថា ថា

នោ ចេ អស្ស សកា ពុទ្ធិ
វិនយោ វា សុសិក្ខិតោ
វនេ អន្ធមហឹសោវ
ចរេយ្យ ពហុកោ ជនោ។

ប្រសិនបើប្រាជ្ញារបស់ខ្លួនក្ដី វិន័យដែលសិក្សាល្អក្ដី មិនមានទេ ជនច្រើនគ្នាតែងប្រព្រឹត្ត ដូចជាក្របីខ្វាក់ ក្នុងព្រៃ ។

# គន្ធារជាតក

យស្មា ច បណ្ឌិតេកាច្ចេ
អាចារម្ហិ សុសិក្ខិតា
តស្មា វិនីតវិនយា
ចរន្តិ សុសមាហិតា ។

មួយទៀត ពួកជនខ្លះ ក្នុងលោកនេះ បាន សិក្សាល្អ ក្នុងអាចារប្បញ្ញត្តិ ព្រោះហេតុនោះ ( ធីរៈជន) អ្នកមានវិន័យទូន្មានហើយ រមែងមានចិត្តតាំងមាំល្អ ។

គាថានេះមានសេចក្ដីថា ម្នាលសម្លាញ់វេទេហៈ ព្រោះថា ប្រសិនបើសត្វទាំងនេះ មិនមានបញ្ញា ឬមិនមានវិន័យ គឺអាចារប្បញ្ញត្តិដែលសិក្សាល្អហើយ ព្រោះអាស្រ័យពួកបណ្ឌិតឲ្យឱវាទទេ កាលបើដូច្នោះ មនុស្សជាច្រើនក៏នឹងដូចអ្នក ដូចក្របីខ្វាក់ មិនដឹង

# គន្ធារជាតក

ទីដែលជាទីគោចរ ឬទីអគោចរ មានវត្ថុដែលគួររង្កៀស ឬមិនមានវត្ថុដែលគួររង្កៀស ត្រាច់ទៅក្នុងព្រៃ មានស្មៅនិងវល្លិជាដើម ប៉ុន្តែព្រោះហេតុ ដែលសត្វពួកខ្លះក្នុងលោកនេះ ដែលប្រាសចាកបញ្ញារបស់ខ្លួន តែបានសិក្សាល្អហើយ ដោយអាចារបញ្ញត្តិ ក្នុងសម្នាក់អាចារ្យ ព្រោះហេតុនោះ សត្វទាំងនោះឈ្មោះថា មានវិន័យដែលណែនាំល្អហើយ ព្រោះខ្លួនជាបុគ្គល ដែលអាចារ្យណែនាំល្អហើយ ដោយវិន័យដ៏សមគួរ គឺជាអ្នកមានចិត្តតាំងមាំហើយ បានដល់ អ្នកមានចិត្តជាសមាធិត្រាច់ទៅ ។

ដោយគាថានេះ គន្ធារតាបសសម្តែងពាក្យនេះទុកថា ពិតណាស់ ជនជាគ្រហស្ថក៏សិក្សាសិក្ខា ដ៏សមគួរដល់ត្រកូលរបស់ខ្លួន ជាបព្វជិតក៏សិក្សាសិក្ខាដែល

# គន្ធារជាតក

*សមគួរដល់បព្វជិត អធិប្បាយថា ចំណែកគ្រហស្ថជាអ្នកសិក្សាក្នុងកសិកម្មនិងគោរក្ខកម្មជាដើម ដែលសមគួរដល់ត្រកូលរបស់ខ្លួនហើយ ក៏នឹងជាអ្នកមានការរស់ដ៏បរិបូណ៌ មានចិត្តតាំងមាំត្រាច់ទៅ ។ ចំណែកបព្វជិតជាអ្នកសិក្សាអំពីអាចារៈ មានការឈានទៅមុខ និងការឈានថយក្រោយជាដើម ហើយសិក្សាអំពីអធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិបញ្ញាសិក្ខាទាំងឡាយ ដែលសមគួរដល់បព្វជិត ដែលគួរឲ្យជ្រះថ្លា ហើយក៏ជាអ្នកប្រាសចាកការរាយមាយ មានចិត្តតាំងមាំ ព្រោះថា ក្នុងលោកនេះ*

> ពាហុសច្ចញ្ច សិប្បញ្ច,
> វិនយោ ច សុសិក្ខិតោ;
> សុភាសិតា ច យា វាចា,
> ឯតំ មង្គលមុត្តមំ។

# គន្ធារជាតក

*ភាវៈនៃបុគ្គលបានស្ដាប់បានរៀនច្រើន ១ សិល្បៈគឺសេចក្ដីឆ្លៀវឆ្លាស ក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាប្រពៃ ១ វាចាដែល បុគ្គលពោលល្អ ១ នេះជាមង្គលដ៏ឧត្តម[១] ។*

វិទេហតាបសបានស្ដាប់ពាក្យនោះហើយ ថ្វាយបង្គំសូមទោសព្រះ មហាសត្វថា "បពិត្រអាចារ្យ ចាប់ពីពេលនេះទៅ សូមលោកចូរដាស់តឿន ចូរប្រៀនប្រដៅខ្ញុំចុះ ខ្ញុំពោលនឹងលោក ព្រោះភាពជាអ្នកមិនមានសេចក្ដីអត់ធន់ សូមលោកចូរអត់ទោសដល់ខ្ញុំផង" ។ តាបសទាំង ២ រូបនោះ រស់នៅសាមគ្គីគ្នាហើយ បាននាំគ្នាទៅព្រៃហិមពាន្តវិញទៀត ។ នៅទីនោះ ព្រះពោធិសត្វបានប្រាប់កសិណបរិកម្ម ដល់

---

[១]. ខុទ្ទកបាឋ. បិដកលេខ ៥២ ទំព័រ ៤ ។

## គន្ធារជាតក

វិទេហតាបស ។ វិទេហតាបសស្តាប់ហើយ បានញ៉ាំង អភិញ្ញានិងសមាបត្តិឲ្យកើតឡើង ។ តាបសទាំង ២ រូប នោះ ជាអ្នកមានឈានមិនសាបសូន្យ ក្រោយអំពី ចុតិ ក៏មានព្រហ្មលោកជាទីទៅខាងមុខ ។

## ជាតកភាវសាន

ព្រះបរមសាស្តា លុះទ្រង់នាំយកព្រះធម្ម ទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតក ថា ព្រះបាទវេទេហៈក្នុងកាលនោះ បានមកជាអានន្ទ, ចំណែកព្រះបាទគន្ធារៈ គឺ **តថាគត** នេះឯង ៕

ចប់ គន្ធារជាតក ។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក សត្តក-និបាត គន្ធារវគ្គ គន្ធារជាតកវណ្ណនា)



បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោសថា ដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នេះ គួរគប់អ្នកប្រាជ្ញបែបនោះ (ព្រោះថា) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្ដីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។